**នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

| | |
|---|---|
| សំណុំរឿងលេខ៖ | ០០៤/០២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស |
| ភាគីដាក់ឯកសារ៖ | អោ អាន |
| ដាក់ជូន៖ | សហចៅក្រមស៊ើបអង្កេត |
| ភាសាដើម៖ | អង់គ្លេស |
| កាលបរិច្ឆេទឯកសារ៖ | ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ |

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 23-Mar-2020, 11:00
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ សម្ងាត់

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស.៖ **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**សំណើសុំដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ**

---

**ដាក់ដោយ÷**

**សហមេធាវីការពារក្តី**
មុំ លុដ្ឋ
Richard ROGERS
Göran SLUITER

**ផ្ញើជូន÷**

**សហចៅក្រមស៊ើបអង្កេត**
ចៅក្រម យូ ប៊ុនឡេង

**សហព្រះរាជអាជ្ញា**
ជា លាង
Brenda HOLLIS

**អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង ០០៤/០២**

# សេចក្តីផ្តើម

1. អោ អាន តាមរយៈសហមេធាវីរបស់ខ្លួន ("*មេធាវីការពារក្តី*") សូមគោរពស្នើសុំឱ្យការិយាល័យសហចៅក្រមស៊ើបអង្កេត ដាក់សំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ អនុលោមតាមវិធាន ៦៩(២)(ខ) នៃវិធានផ្ទៃក្នុង("*វិធានផ្ទៃក្នុង*") នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ រឿងក្តីប្រឆាំងនឹង អោ អាន ត្រូវបានលើកលែងការចោទប្រកាន់នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨[1] ហើយដីកាសម្រេចលើកលែងការចោទប្រកាន់ពុំត្រូវបានច្រានចោលនៅក្នុងដំណាក់កាលប្តឹងឧទ្ធរណ៍កាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ នោះឡើយ[2]។ អនុលោមតាមវិធាន ៧៧(១៣)(ក)*ដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន* ("*ដីកាលើកលែងការចោទប្រកាន់*") នៅបន្តមានសុពលភាព ហើយអនុលោមតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា ("រដ្ឋធម្មនុញ្ញកម្ពុជា") រឿងក្តីនេះត្រូវបានបញ្ចប់។ នៅក្នុងកាលៈទេសៈបែបនេះ វិធាន ៦៩(២)(ខ) តម្រូវឱ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ។

2. យោងតាមព័ត៌មានដែលចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ[3] បានផ្សព្វផ្សាយ អង្គបុរេជំនុំជម្រះ ខកខានក្នុងការដោះស្រាយលើការខ្វែងយោបល់គ្នាផ្ទៃក្នុង ហើយបច្ចុប្បន្នបានឈានដល់ការអនុវត្តសិទ្ធិអំណាចក្នុងការសម្រេចលើលទ្ធផលនៃសំណុំរឿង០០៤/២[4]។ ការិយាល័យរដ្ឋបាល ("*ការិយាល័យរដ្ឋបាល*") បានទទួលការណែនាំផ្ទុយគ្នាពីចៅក្រម ហើយមិនអាចចាត់វិធានការបានទេ[5]។ អង្គជំនុំជម្រះសាលាដំបូងដែលពុំទាន់បានទទួលរឿងក្តីនេះស្របតាមច្បាប់នៅឡើយ ហើយនៅពុំទាន់មានសិទ្ធិ

---

[1] សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អវតក/កសចស *ដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន ("ដីកាសម្រេចលើកលែងការចោទប្រកាន់")* ឯកសារ **D359** ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។

[2] សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អវតក/កសចស (អបជ ៦០) *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ("សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍")* ឯកសារ **D359/24 & D360/33** ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩។

[3] *អនុស្សរណៈអន្តរការិយាល័យចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ពាក់ព័ន្ធនឹងការផ្ទេរសំណុំរឿង ០០៤/២ ("អនុស្សរណៈចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០")* ត្រូវបានចៅក្រមអន្តរជាតិ អង្គបុរេជំនុំជម្រះ បញ្ជូនទៅភាគី ទំព័រ ១ ដែលបានដាក់ភ្ជាប់ជាឧបសម្ព័ន្ធ ១។

[4] *អនុស្សរណៈចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០* កថាខណ្ឌ ២៧ កថាខណ្ឌ ៣៣។

[5] *អនុស្សរណៈអន្តរការិយាល័យចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ សំណើសុំបញ្ជាក់បំភ្លឺអនុលោមតាមវិធាន ១០(២) ("អនុស្សរណៈចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០")* ត្រូវបញ្ជូនដោយ ក្រាញ់ តូនី ប្រធានការិយាល័យរដ្ឋបាលស្តីទី និង *Knut Rosandhaug* អនុប្រធានការិយាល័យរដ្ឋបាល កថាខណ្ឌ ១៣ ដែលបានដាក់ភ្ជាប់ជាឧបសម្ព័ន្ធ ២។

ចូលពិនិត្យមើលសំណុំរឿង ក៏ពុំអាចបំពេញកិច្ចបានដូចគ្នា[6]។ ភាពមិនច្បាស់លាស់នាពេលបច្ចុប្បន្ន រំលោភសិទ្ធិរបស់ អោ អាន ក្នុងការទទួលបានការសម្រេចចុងក្រោយលើរឿងក្ដីរបស់ខ្លួន គោលការណ៍សច្ចភាពផ្លូវច្បាប់ហើយបន្តប៉ះពាល់ដល់សុខមាលភាពរបស់គាត់។ ការិយាល័យសហចៅក្រមស៊ើបអង្កេត ក៏ជាអង្គភាពតុលាការនៃ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលតែមួយគត់ ទទួលអំណាចតាមវិធានផ្ទៃក្នុងអាចដោះស្រាយការជាប់គាំងនាពេលបច្ចុប្បន្ននេះ។ អាស្រ័យហេតុនេះ មេធាវីការពារក្ដីសូមគោរពស្នើសុំឱ្យ ការិយាល័យសហចៅក្រមស៊ើបអង្កេត ដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ ស្របតាមវិធាន ៦៩(២)(ខ) និងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា។

3. មេធាវីការពារក្ដីដាក់សំណើសុំនេះជាភាសាអង់គ្លេសជាមុនសិន ដោយសំណៅបកប្រែជាភាសាខ្មែរនឹងត្រូវដាក់ជូនតាមក្រោយឱ្យបានឆាប់បំផុត។

## ប្រវត្តិនីតិវិធី

4. នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយចំនួនពីរផ្ទុយគ្នា និងដាច់ដោយឡែកពីគ្នានៅក្នុងសំណុំរឿង ០០៤/០២[7]។

5. នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨ សហព្រះរាជអាជ្ញាជាតិបានដាក់សេចក្ដីសន្និដ្ឋានលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (*ដីកាបញ្ជូនរឿងទៅជំនុំជម្រះ*)[8]។ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ សហព្រះរាជអាជ្ញាជាតិបានដាក់សេចក្ដីសន្និដ្ឋានលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាលើកលែងការចោទប្រកាន់[9]។ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ មេធាវីការពារក្ដីក៏បានដាក់សេចក្ដីសន្និដ្ឋានលើបណ្ដឹង

---

[6] *អ៊ីមែលពីក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងផ្ញើជូនភាគីពាក់ព័ន្ធនឹងសំណុំរឿង ០០៤/២ ("អ៊ីមែលពីក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០")* ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នា២០២០ ដែលបានដាក់ភ្ជាប់ជាឧបសម្ព័ន្ធ ៣។

[7] សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អវតក/កសចស *ដីកាដំណោះស្រាយ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ")* ឯកសារ **D360** ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។ *ដីកាសម្រេចលើកលែងការចោទប្រកាន់*។

[8] សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អវតក/កសចស (អបជ ៦០) *បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិទាក់ទងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងសំណុំរឿង ០០៤/២* ឯកសារ **D359/8/1** ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ ២០១៨។

[9] សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អវតក/កសចស (អបជ ៦០) *បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើកលែងការចោទប្រកាន់ អោ អាន ("បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ")* ឯកសារ **D359/3/1**

ឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (*ដីកាលើកលែងការចោទប្រកាន់*)ផងដែរ[10]។

6. នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះ បានចេញសេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (*សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍*)។ អង្គបុរេជំនុំជម្រះ បានសម្រេចជាឯកច្ឆ័ន្ទថា ការចេញដីកាដំណោះស្រាយចំនួនពីរផ្ទុយគ្នាគឺខុសច្បាប់ ហើយអង្គបុរេជំនុំជម្រះ ខកខានក្នុងការឈានទៅរកសម្លេងភាគច្រើនលើសលប់លើអង្គសេចក្តីនៃសេចក្តីសន្និដ្ឋានរបស់ភាគីលើបណ្តឹងឧទ្ធរណ៍[11]។

7. នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ មេធាវីការពារក្តីបានចេញលិខិតទៅអង្គជំនុំជម្រះសាលាដំបូងស្នើសុំការបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងពុំបានទទួលសំណុំរឿង ០០៤/២ ស្របច្បាប់នោះទេ ហើយអាចនិយាយម្យ៉ាងទៀតថា មេធាវីការពារក្តី មានបំណងស្នើសុំពន្យារពេល និងគោលការណ៍ណែនាំសម្រាប់ការដាក់អញ្ញត្រកម្មនអនុលោមតាមវិធាន ៨៩[12]។

8. នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង បានផ្ញើអ៊ីមែលជូនទៅភាគីបញ្ជាក់ថា អង្គបុរេជំនុំជម្រះ ពុំទាន់បានបញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូងនៅឡើយនោះទេ[13]។

9. នៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២០[14] សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់*សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំឲ្យចាត់វាល់វិធានការរដ្ឋបាលដែលតម្រូវទាំងអស់ ដើម្បីបញ្ជូនសំណុំរឿង ០០៤/២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង* (“*សំណើសុំរបស់សហព្រះរាជអាជ្ញាអន្តរជាតិ*

---

ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨។

[10] សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អវតក/កសចស (អបជ ៦០) *បណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងដីកាសម្រេចលើដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (“ដីកាបញ្ជូនរឿងទៅជំនុំជម្រះ”)* ឯកសារ **D360/5/1** ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨។

[11] *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍* កថាខណ្ឌ ១២៤ កថាខណ្ឌ ១៦៩។

[12] ក្រុមមេធាវីការពារក្តី អោ អាន “*សំណើសុំបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងពុំបានទទួលស្របច្បាប់នូវសំណុំរឿង ០០៤/២ ឬ សំណើសុំពន្យារពេល និងគោលការណ៍ណែនាំសម្រាប់ការដាក់អញ្ញត្រកម្មអនុលោមតាមវិធាន ៨៩* ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ ដែលត្រូវបានដាក់ភ្ជាប់ជាឧបសម្ព័ន្ធ ៤។

[13] *អ៊ីមែលពីក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំពូងផ្ញើជូនភាគីពាក់ព័ន្ធនឹងសំណុំរឿង ០០៤/២* ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ ដែលបានដាក់ភ្ជាប់ជាឧបសម្ព័ន្ធ ៥។

[14] ឯកសារនេះត្រូវបានជូនដំណឹងទៅមេធាវីការពារក្តីនៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០។

*ស៊ុំចាត់វិធានការ'*)[15]។ មេធាវីការពារក្តីបានដាក់ចម្លើយតបទៅនឹង*សំណើសុំរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស៊ុំចាត់វិធានការ* នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០[16]។ សហព្រះរាជអាជ្ញាអន្តរជាតិបានឆ្លើយតបទៅនឹងការឆ្លើយតបរបស់មេធាវីការពារក្តីនៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០២០[17]។

10. នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងបានបញ្ជូនអ៊ីមែលមួយទៀតដើម្បីបញ្ជាក់ជូនភាគីទាំងអស់សាជាថ្មីថា អង្គបុរេជំនុំជម្រះ ពុំទាន់បានបញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូងនៅឡើយនោះទេ[18]។

11. នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០ មេធាវីការពារក្តីបានដាក់*សំណើសុំការបញ្ជាក់ថាបានចាត់វិធានការរដ្ឋបាលដែលចាំបាច់ទាំងអស់ដើម្បីរក្សាសំណុំរឿង ០០៤/២ ទុកក្នុងបណ្ណសារ*[19]។ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ចម្លើយតបទៅនឹងសំណើសុំរបស់មេធាវីការពារក្តីកាលពីថ្ងៃទី៥ ខែមីនា ឆ្នាំ២០២០[20]។ មេធាវីការពារក្តីបានដាក់ការឆ្លើយតបកាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០[21]។

---

[15] សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អវតក/អជសជ *សំណើសុំរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំចាត់រាល់វិធានការរដ្ឋបាលដែលតម្រូវទាំងអស់ដើម្បីបញ្ជូនសំណុំរឿង ០០៤/២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង ("សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ច")* ឯកសារ **D359/25 & D360/34** ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០។

[16] សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អវតក/អជសជ *ចម្លើយតបទៅនឹងសំណើសុំរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំចាត់រាល់វិធានការរដ្ឋបាលដែលតម្រូវទាំងអស់ដើម្បីបញ្ជូនសំណុំរឿង ០០៤/២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង* ឯកសារ **D359/26 & D360/35** ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០។

[17] សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អវតក/អជសជ *ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងចម្លើយតបរបស់ អោ អាន ទៅនឹងសំណើសុំរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំចាត់រាល់វិធានការរដ្ឋបាលដែលតម្រូវទាំងអស់ដើម្បីបញ្ជូនសំណុំរឿង ០០៤/២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង* ឯកសារ **D359/28 & D360/37** ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០២០។

[18] អ៊ីមែលពីក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០។

[19] សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អវតក/កសចស (អបជ ៦០) *សំណើសុំការបញ្ជាក់ថាបានចាត់វិធានការរដ្ឋបាលដែលចាំបាច់ទាំងអស់ដើម្បីរក្សាសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ* ឯកសារ **D359/27 & D360/36** ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០។

[20] សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អវតក/កសចស (អបជ ៦០) *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់ អោ អាន ស្នើសុំការបញ្ជាក់ថាបានចាត់វិធានការរដ្ឋបាលដែលចាំបាច់ទាំងអស់ដើម្បីរក្សាសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ* ឯកសារ D359/30 & D360/39 ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០២០។

[21] សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អវតក/កសចស (អបជ ៦០) *ការឆ្លើយទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់ អោ អាន ស្នើសុំការបញ្ជាក់ថាបានចាត់វិធានការរដ្ឋបាលដែលចាំបាច់ទាំងអស់ដើម្បីរក្សាសំណុំរឿង*

12. នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ចៅក្រមអន្តរជាតិនៃ អង្គបុរេជំនុំជម្រះ បានចេញ*អនុស្សរណៈអន្តរការិយាល័យស្តីពីការផ្ទេរសំណុំរឿង ០០៤/២* ដោយភ្ជាប់មកជាមួយនូវឧបសម្ព័ន្ធចំនួន ០៨[22]។

## ច្បាប់ជាធរមាន

13. វិធាន ៦៩(២)(ខ) ចែងថា "នៅពេលដែលគ្មាបណ្តឹងឧទ្ធរណ៍ សហចៅក្រមស៊ើបអង្កេតត្រូវបិទសំណុំរឿងដោយមានបោះត្រាលើសំណុំរឿង និង [...] ប្រសិនបើមានដីកាលើកលែងការចោទប្រកាន់ សំណុំរឿងត្រូវបានរក្សាទុកក្នុងបណ្ណសារ ក្រោយផុតរយៈពេលធ្វើបណ្តឹងឧទ្ធរណ៍"។ ពុំមានបទប្បញ្ញត្តិប្រហាក់ប្រហែលគ្នាសម្រាប់ស្ថានភាព ដែលដីកាលើកលែងការចោទប្រកាន់ត្រូវបានតម្កល់ ឬពុំត្រូវបានច្រានចោលនៅក្នុងដំណាក់កាលបណ្តឹងឧទ្ធរណ៍នោះទេ (*គឺ* ដោយសេចក្តីសម្រេចរបស់ អង្គបុរេជំនុំជម្រះ ឬ ដោយសារការខកខានរបស់អង្គជំនុំជម្រះក្នុងការទទួលបានសម្លេងភាគច្រើនលើសលប់)។ ដូច្នេះ វិធាន ៦៩(២)(ខ) ត្រូវអនុវត្ត *ដូចគ្នាដោយគ្មានការកែប្រែ* ចំពោះស្ថានភាពបច្ចុប្បន្ន។

14. វិធាន ៧៧(១៣)(ក) ចែងថា ប្រសិនបើសម្លេងភាគច្រើនលើសលប់ពុំអាចទទួលបានចំពោះ*បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចក្រៅពីដីកាបញ្ជូនរឿងទៅជំនុំជម្រះ* សេចក្តីសម្រេចដែលពុំអាចរកសម្លេងបាននោះ មានន័យថា ដីកាសម្រេចនោះត្រូវចាត់ទុកជាបានការ។

15. មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចែងថាករណីវិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។ គោលការណ៍ដូចគ្នានេះត្រូវបានទទួលស្គាល់ជាសាកល ដូចមានចែងនៅក្នុងមាត្រា ១៤(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីពលរដ្ឋ និងសិទ្ធិនយោបាយ។

16. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ មានចែងនៅក្នុងមាត្រា ១៣ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ រាជធានីភ្នំពេញ ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ("*កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា*") មាត្រា ៣៣ ដល់ មាត្រា ៣៥ នៃច្បាប់ស្តីពីបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលបានធ្វើ

---

*០០៤/២ ទៅក្នុងបណ្ណសារ* ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០។

[22] អនុស្សរណៈចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០។

វិសោធនកម្មនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ("*ច្បាប់ អ.វ.ត.ក*") និងវិធាន ២១[23]។

## សំណើសុំ

17. មេធាវីការពារក្ដីស្នើសុំឱ្យ ការិយាល័យសហចៅក្រមស៊ើបអង្កេត ដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ អនុលោមតាមវិធាន ៦៩(២)(ខ)។

18. *ដីកាលើកលែងការចោទប្រកាន់* អនុលោមតាមវិធាន ៦៧(២) ត្រូវបានចេញនៅក្នុងសំណុំរឿង ០០៤/២ កាលពីថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹង*ដីកាលើកលែងការចោទប្រកាន់* ក៏ប៉ុន្តែ អង្គបុរេជំនុំជម្រះ ខកខានក្នុងការទទួលបានសម្លេងភាគច្រើនលើសលប់លើអង្គសេចក្ដីនៃបណ្ដឹងឧទ្ធរណ៍នោះ[24]។ អនុលោមតាមវិធាន ៧៧(១៣)(ក) ប្រសិនបើមិនអាចទទួលបានសម្លេងភាគច្រើនលើសលប់ដូចបានតម្រូវចំពោះបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចណាមួយក្រៅពីដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះទេ សេចក្ដីសម្រេចដែលពុំអាចទទួលបានសម្លេងភាគច្រើនលើសលប់នោះ មានន័យថាដីកាសម្រេចនោះត្រូវចាត់ទុកជាបានការ។ ដូច្នេះ *ដីកាលើកលែងការចោទប្រកាន់* បន្តមានអានុភាពអនុវត្ត ដោយមិនមានអានុភាពប៉ះពាល់ដោយសារបណ្ដឹងឧទ្ធរណ៍នោះឡើយ។ ករណីដែលថា ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ក៏អាចចាត់ទុកជាបានការផងដែរ ស្របតាមវិធាន ៧៧(១៣)(ខ) ពុំមានអានុភាពលើការបន្តអនុវត្តដីកាលើកលែងការចោទប្រកាន់នោះទេ (ជាពិសេស យោងតាមគោលការណ៍ដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញស្ដីពី*វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* និងការគាំទ្រពីចៅក្រម អង្គបុរេជំនុំជម្រះ ភាគច្រើនចំពោះការលើកលែងការចោទប្រកាន់លើរឿងក្ដីនោះ។

19. ទោះបីជា អង្គបុរេជំនុំជម្រះ បានសម្រេចជាឯកច្ឆ័ន្ទថា ការចេញដីកាដំណោះស្រាយចំនួនពីរផ្ទុយគ្នា

---

[23] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ រាជធានីភ្នំពេញ ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ("*កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា*") មាត្រា ១៣។ ច្បាប់ស្ដីពីបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលបានធ្វើវិសោធនកម្មនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (នស/រកត/១០០៤/២០០៦) ("*ច្បាប់ អ.វ.ត.ក*") មាត្រា ៣៣ មាត្រា ៣៥។ វិធាន ២១។

[24] *សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍* កថាខណ្ឌ ១៦៩។

និងដោយឡែកពីគ្នា គឺជាការអនុវត្តខុសច្បាប់[25] អង្គបុរេជំនុំជម្រះ មិនអាចមានសម្លេងភាគច្រើនលើសលប់លើអានុភាពនៃនីត្យានុកូលភាព និងផលវិបាកផ្នែកនីតិវិធីចំពោះសំណុំរឿង ០០៤/២[26]។ ចៅក្រម អង្គបុរេជំនុំជម្រះ ភាគច្រើន បានសម្រេចថា គោលការណ៍ដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញស្ដីពី *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* តម្រូវឱ្យលើកលែងការចោទប្រកាន់សំណុំរឿង ០០៤/២[27]។ ចៅក្រម អង្គបុរេជំនុំជម្រះ ភាគតិចមិនឯកភាព។ ទោះបីជាយ៉ាងនេះក្ដី ចៅក្រម អង្គបុរេជំនុំជម្រះ ពីររូប មិនអាចមានអានុភាពលើការយល់ឃើញរបស់ចៅក្រមភាគច្រើន ឬ បង្គាប់ដោយឯកតោភាគីឱ្យក្រឡាបញ្ជីបញ្ជូនរឿងក្ដីទៅអង្គជំនុំជម្រះសាលាដំបូងនោះទេ[28]។

20. ក្របខ័ណ្ឌ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មិនអាចដោះស្រាយភាពជាប់គាំងដែលបានបង្កើតឡើងដោយការចេញដីកាដំណោះស្រាយចំនួនពីរ និងដាច់ដោយឡែក ហើយគ្មានដីកាណាមួយត្រូវបានច្រានចោលនៅបណ្ដឹងឧទ្ធរណ៍ ដោយសម្លេងភាគច្រើនលើសលប់ឡើយ[29]។ អនុលោមតាមគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ដូចមានចែងនៅក្នុងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា និងមាត្រា ១៤(២) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ភាពជាប់គាំង និងភាពមិនប្រាកដប្រជាទាំងអស់ ត្រូវសម្រេចជាប្រយោជន៍ដល់ អោ អាន។ លើសពីនេះទៀត សិទ្ធិរបស់ អោ អាន ក្នុងការទទួលបានការជំនុំជម្រះដោយតុលាការមានសមត្ថកិច្ច ដូចមានកំណត់នៅក្នុងច្បាប់ ចែងថា ការយល់ឃើញរបស់ចៅក្រមភាគច្រើនមិនអាចទុកចោលមិនពិចារណានោះទេ[30]។ ចំណុចចុងក្រោយ យើងគួរកត់សម្គាល់ថា *ដីកាលើកលែងការ*

---

[25] *សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍* កថាខណ្ឌ ១២៣-១២៤។

[26] *សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍* កថាខណ្ឌ ១២៤ កថាខណ្ឌ ១៧០-៣០២ កថាខណ្ឌ ៣០៤-៣២៩។

[27] *សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍* កថាខណ្ឌ ២៩៥-៣០២។

[28] *សំណើសុំរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ច* កថាខណ្ឌ ២៤។ *សូមមើល ការឆ្លើយតបអ៊ីមែលរវាងអង្គបុរេជំនុំជម្រះ និងផ្នែកគ្រប់គ្រងតុលាការ* (“*ការឆ្លើយឆ្លងអ៊ីមែលរវាងអង្គបុរេជំនុំជម្រះ និងផ្នែកគ្រប់គ្រងតុលាការ*”) ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ ដែលត្រូវបានដាក់ភ្ជាប់ជាឧបសម្ព័ន្ធទី ៦។

[29] *សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ២៩៥-៣០២*។

[30] សិទ្ធិនេះពុំមែនត្រឹមតែជាទម្រង់ប៉ុណ្ណោះនោះទេ ហើយតម្រូវអនុវត្តស្របតាមនិយាមជាមូលដ្ឋានស្ដីពីដំណើរការត្រឹមត្រូវតាមផ្លូវច្បាប់ផងដែរ៖ គណៈកម្មាធិការសិទ្ធិមនុស្ស មតិយោបល់ទូទៅលេខ ៣២ មាត្រា ១៤៖ សិទ្ធិសមភាពចំពោះមុខតុលាការ និងសាលាក្ដី និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ឯកសារ អ.ស.ប CCPR/C/GC/32 (ឆ្នាំ២០០៧) កថាខណ្ឌ ១៨ ដែលត្រូវបានដាក់ភ្ជាប់ជាឧបសម្ព័ន្ធទី ៧។ រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Karadžić* សាលក្រមស្ដីពីបណ្ដឹងរបស់ជនជាប់ចោទតវ៉ាសុពលភាពផ្លូវច្បាប់ និងនីត្យានុកូលភាពនៃសាលាក្ដី ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០៩ កថាខណ្ឌ ១៣ ដែលត្រូវបានដាក់ភ្ជាប់ជាឧបសម្ព័ន្ធលេខ

*ចោទប្រកាន់* ត្រូវបានចុះបញ្ជីក្នុងសំណុំរឿងនៅមុនពេលមាន*ដីកាដំណោះស្រាយ* (*ដីកាបញ្ជូនរឿងទៅជំនុំជម្រះ*)។ ហេតុដូច្នេះ *ដីកាលើកលែងការចោទប្រកាន់* ដែលទទួលប្រយោជន៍ពីការគាំទ្ររបស់ចៅក្រមភាគច្រើន ហើយសហព្រះរាជអាជ្ញាជាតិត្រូវមានអានុភាពលើ*ដីកាដំណោះស្រាយ* (*ដីកាបញ្ជូនរឿងទៅជំនុំជម្រះ*)។ អាស្រ័យហេតុនេះ រឿងក្តីប្រឆាំងនឹង អោ អាន ត្រូវបានច្រានចោលប្រកបដោយប្រសិទ្ធភាព។

21. យោងតាមវិធាន ៦៩(២)(ខ) "ប្រសិនបើមានដីកាលើកលែងការចោទប្រកាន់ សំណុំរឿងត្រូវបានរក្សាទុកក្នុងបណ្ណសារ"។ ទោះបីជាវិធាន ៦៩(២)(ខ) អនុវត្តយ៉ាងច្បាស់លាស់លើស្ថានភាពដែលគ្មានបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាលើកលែងការចោទប្រកាន់ ពុំមានបទប្បញ្ញត្តិប្រហាក់ប្រហែលគ្នាចំពោះស្ថានភាពដែលមានការតម្កល់ ឬច្រានចោលដីកាលើកលែងការចោទប្រកាន់នៅក្នុងដំណាក់កាលបណ្តឹងឧទ្ធរណ៍ (*គឺ* តាមរយៈសម្លេងភាគច្រើនលើសលប់របស់ អង្គបុរេជំនុំជម្រះ ឬ ដោយសារអង្គបុរេជំនុំជម្រះ ខកខានមិនបានទទួលសម្លេងភាគច្រើនលើសលប់បាន)។ តាមភាពសមស្រប ក្នុងកាលៈទេសៈបែបនេះ សំណុំរឿងត្រូវទទួលបានការដាក់បញ្ចូលទៅក្នុងបណ្ណសារស្របតាមវិធាន ៦៩(២)(ខ)។

22. អនុលោមតាមវិធាន ៦៩(២)(ខ) វាអាស្រ័យលើ ការិយាល័យសហចៅក្រមស៊ើបអង្កេតក្នុងការដាក់សំណុំរឿងបញ្ចូលទៅក្នុងបណ្ណសារ។ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ បានបញ្ជាក់ថា "*ក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះបានដាក់ទម្រង់បែបបទនៃការដាក់ឯកសារ និងការណែនាំអំពីការជូនដំណឹងភ្លាមៗក្រោយពីបានចេញសេចក្តីពិចារណា ដោយបានបង្គាប់ឲ្យអង្គភាពបណ្ណសារដាក់សេចក្តីពិចារណាជាសាធារណៈ និងជូនដំណឹងអំពីសេចក្តីពិចារណាទៅការិយាល័យសហចៅក្រមស៊ើបអង្កេត និងភាគីនៅក្នុងសំណុំរឿង ០០៤/២*"[31]។ នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ ក្រឡាបញ្ជី អង្គបុរេ

---

៨ ("[...] តុលាការព្រហ្មទណ្ឌអន្តរជាតិត្រូវបាន "បង្កើតឡើងដោយច្បាប់" នៅពេលវា "បានកើតឡើងចេញពីវិធាននៃច្បាប់ ហើយផ្តល់ការធានាទាំងអស់ ដែលមានចែងនៅក្នុងលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធ"") (ដកស្រង់ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Tadić,* IT-94-1-AR72 *សាលដីកាស្តីពីបណ្តឹងរបស់មេធាវីការពារក្តីចំពោះបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំលើយុត្តាធិការ* ចុះថ្ងៃទី២ ខែតុលា ឆ្នាំ១៩៩៥ កថាខណ្ឌ ១០-១២)។ រឿងក្តី *Richert ទល់នឹង ប្រទេសប៉ូឡូញ* តុលាការសិទ្ធិមនុស្សអឺរ៉ុប បណ្តឹងលេខ ៥៤៨០៩/០៧ សាលដីកា ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១២ កថាខណ្ឌ ៤៣ ដែលត្រូវបានដាក់ភ្ជាប់ជាឧបសម្ព័ន្ធ ៩ ("សាលាក្តីបង្កើតឡើងដោយច្បាប់ ត្រូវបំពេញលក្ខខណ្ឌមួយចំនួន ដូចជា ឯករាជ្យនៃសមាជិក និងកំណត់រយៈពេលកាន់តំណែង អព្យាក្រឹត្យភាព និងអត្ថិភាពនៃការធានាផ្នែកនីតិវិធី")។

[31] អនុស្សរណៈចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ កថាខណ្ឌ ២៧។

ជំនុំជម្រះ អនុវត្តស្របតាមការណែនាំរបស់ចៅក្រមភាគច្រើន បានបញ្ជាក់ថា "*សំណុំរឿង ០០៤/២ នេះត្រូវបានបញ្ចប់*"[32]។ ទោះបីជាយ៉ាងនេះក្តី អង្គបុរេជំនុំជម្រះ ដែលមិនអាចដំណើរការទៅមុខ ដោយសារការខ្វែងយោបល់ផ្ទៃក្នុង បានឈានដល់ការប្រើប្រាស់អំណាចសម្រេចលើលទ្ធផលនៃ សំណុំរឿង ០០៤/២[33] អោ អាន មិនអាចអនុវត្តការងារតាមការណែនាំផ្ទុយគ្នារបស់ចៅក្រមនោះទេ[34] ហើយ អង្គជំនុំជម្រះសាលាដំបូង ពុំបានទទួលរឿងក្តីដោយស្របច្បាប់ ហើយមិនទទួលបានសិទ្ធិ ចូលពិនិត្យមើលសំណុំរឿងនោះទេ[35]។ ដូច្នេះ ការិយាល័យសហចៅក្រមស៊ើបអង្កេតគឺជាអង្គភាព តុលាការរបស់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា តែមួយគត់ ដែលមានអំណាចតាមវិធាន ផ្ទៃក្នុង ក្នុងការដោះស្រាយភាពជាប់គាំងនាពេលបច្ចុប្បន្ននេះ។

23. មកទល់ពេលនេះ អោ អាន មិនបានទទួលការបញ្ជាក់ថា សំណុំរឿង ០០៤/២ ត្រូវបានដាក់សំណុំ រឿងបញ្ចូលទៅក្នុងបណ្ណសារតាមលក្ខខណ្ឌតម្រូវនៃវិធានផ្ទៃក្នុងឡើយ។ លទ្ធផលនៃភាពមិនច្បាស់ លាស់នេះរំលោភសិទ្ធិរបស់ អោ អាន ក្នុងការទទួលបានការសម្រេចចុងក្រោយលើសំណុំរឿង គោល ការណ៍សច្ចភាពផ្លូវច្បាប់ និងបន្តប៉ះពាល់លើសុខុមាលភាពរបស់គាត់។

24. យោងតាមយុត្តិសាស្ត្រដែលគួរឱ្យជឿជាក់របស់តុលាការសិទ្ធិមនុស្សអឺរ៉ុប ("*តុលាការសិទ្ធិមនុស្ស អឺរ៉ុប*") ការធានាជាមូលដ្ឋាននៃការជំនុំជម្រះដោយយុត្តិធម៌ (ដូចមានចែងនៅក្នុងមាត្រា ១៣ នៃកិច្ច ព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា និងមាត្រា ៣៣ ដល់ មាត្រា ៣៥ នៃ ច្បាប់ អ.វ.ត.ក) "*រួមមានសិទ្ធិក្នុងការទទួលបានការសម្រេចចុងក្រោយ លើបញ្ហាដែលបានដាក់ជូន តុលាការ*"[36]។ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចទៀតថា "*ការរៀបចំតាមសម្លេងបោះឆ្នោតដូច បានកំណត់ [...] ពុំមែនជាប្រយោជន៍នៃសច្ចភាព និងអាចដកហូតសិទ្ធិប្រកបដោយប្រសិទ្ធភាព របស់ [ជនជាប់ចោទ] ក្នុងការទទួលបានការសម្រេចជាស្ថាពរលើ [រឿងក្តី] របស់ខ្លួន [ឈានទៅ កម្រិតលើ] ស្មារតីនៃសិទ្ធិរបស់ជនជាប់ចោទក្នុងប្តឹងទៅតុលាការ*" ហេតុដូច្នេះ វាជាការបំពានលើ

---

[32] *ការឆ្លើយឆ្លងអ៊ីមែលរវាងអង្គបុរេជំនុំជម្រះ និងផ្នែកគ្រប់គ្រងតុលាការ*។

[33] អនុស្សរណៈចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ កថាខណ្ឌ ២៧ កថាខណ្ឌ ៣៣។

[34] អនុស្សរណៈចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ កថាខណ្ឌ ១៣។

[35] អ៊ីមែលពីក្រឡាបញ្ជីរបស់ អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០។

[36] រឿងក្តី Marini ទល់នឹង អាល់បានី តុលាការសិទ្ធិមនុស្សអឺរ៉ុប សាលដីកា បណ្តឹងលេខ ៣៧៣៨/០២ ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ ២០០៨ កថាខណ្ឌ ១២០ ដែលត្រូវបានដាក់ភ្ជាប់ជាឧបសម្ព័ន្ធលេខ ១០។

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌[37]។

25. ម្យ៉ាងវិញទៀត ការខ្វះសច្ចភាពចំពោះលទ្ធផលចុងក្រោយនៃសំណុំរឿង ០០៤/២ គឺជាការរារាំងសិទ្ធិរបស់ អោ អាន ក្នុងទទួលបានការជំនុំជម្រះលើរឿងក្ដីរបស់ខ្លួន ដោយតុលាការមានសមត្ថកិច្ច ដែលបានបង្កើតឡើងដោយច្បាប់។ លទ្ធផលនៃភាពមិនប្រាកដប្រជានេះ មិនថាគាត់នៅបន្តប្រឈមនឹងបទចោទពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មទ្រង់ទ្រាយធំ រួមទាំង បទប្រល័យពូជសាសន៍ បន្តប៉ះពាល់លើសុខុមាលភាពរបស់ អោ អាន។ ជនជាប់ចោទមិនគួរក្លាយជាចំណាប់ខ្មាំងដោយសារតុលាការមិនអាចដំណើរការទៅមុខបាននោះទេ មិនថាអង្គភាពណាជាអ្នកទទួលខុសត្រូវលើភាពជាប់គាំងនេះទេ។

## សេចក្ដីសន្និដ្ឋាន និងសំណើសុំ

26. អាស្រ័យហេតុនេះ មេធាវីការពារក្ដីសូមគោរពស្នើសុំឱ្យ ការិយាល័យសហចៅក្រមស៊ើបអង្កេត ដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ។

សូមលោក លោកស្រីចៅក្រម មេត្តាទទួលយកដោយសេចក្ដីគោរព។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០

**សហមេធាវីការពារក្ដី អោ អាន**

| | | |
|---|---|---|
| មុំ លុយ្ស | Richard ROGERS | Göran SLUITER |

[37] រឿងក្ដី Marini កថាខណ្ឌ ១២២-១២៣។